## ព័ត៌មានទូទៅអំពីមូលនិធិ ស.អ. ឬ CBR&D

**មូលនិធិ ស.អ.** ឬ ហៅពេញថា មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន គឺជាមូលនិធិ ដែលបង្កើតឡើងដោយច្បាប់ស្តីពីទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដើម្បីទ្រទ្រង់ និងលើកកម្ពស់ដល់ការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការទ្រទ្រង់វិស័យទាំងមូល ក៏ដូចជាដើម្បីការកសាងឧស្សាហកម្មនេះនៅកម្ពុជាប្រកបដោយភាពប្រកួតប្រជែងក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថល។ **មូលនិធិស.អ.** នេះ ស្ថិតនៅក្រោមការគ្រប់គ្រង ការចាត់ចែង និងការទទួលខុសត្រូវ របស់**ក្រុមប្រឹក្សាភិបាលមូលនិធិ ស.អ.** ដែលត្រូវបានតែងតាំងដោយសេចក្តីសម្រេចលេខ៦៨ សសរ. ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ ស្តីពី "ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលមូលនិធិ នៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន" ។

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានសមាសភាព៧រូប ដែលមានរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាប្រធាន, រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍០១រូប ជាអនុប្រធានទី០១, តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ០១រូប ជាអនុប្រធានទី០២, តំណាងក្រសួងអប់រំ យុវជន និងកីឡា០១រូប ជាសមាជិក, តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ០១រូប ជាសមាជិក, អគ្គនាយកនៃអគ្គនាយកដ្ឋាន បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន០១រូប ជាសមាជិកអចិន្ត្រៃយ៍ និងអគ្គនាយកនៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍០១រូប ជាសមាជិក។ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានការប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំវិសាមញ្ញ តាមគំនិតផ្តួចផ្តើមរបស់ប្រធាន**ក្រុមប្រឹក្សាមូលនិធិ ស.អ.** ឬតាមការស្នើសុំពីសមាជិក **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ចំនួន២/៣ (ពីរភាគបី)។

## ក្រុមប្រឹក្សាមូលនិធិ ស.អ. មានមុខងារ និងភារកិច្ចដូចតទៅ៖

១. គ្រប់គ្រង និងចាត់ចែង**មូលនិធិ ស.អ.**

២. ពិនិត្យ និងអនុម័តលើផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ

៣. លើកកម្ពស់ និងជំរុញការកសាងសមត្ថភាព ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព

៤. ពិនិត្យ និងអនុម័ត លើផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍

៥. ពិនិត្យនិងអនុម័តលើផែនការ និងយន្តការប្រើប្រាស់**មូលនិធិ ស.អ.** និងយន្តការអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងអភិវឌ្ឍ និងនវានុវត្តន៍

៦. ពិនិត្យនិងអនុម័តលើគម្រោង អនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍

៧. គ្រប់គ្រងសមិទ្ធផលដែលទទួលបានពីគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍

៨. តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍនិងនវានុវត្តន៍

៩. រៀបចំរបាយការណ៍ ស្តីពី វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ជូនរដ្ឋាភិបាល

១០. ធ្វើជាតំណាងស្របច្បាប់ របស់**មូលនិធិ ស.អ.** ក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័នរដ្ឋ ឬឯកជនដៃគូជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត

១១. ពិនិត្យនិងអនុម័តការផ្តល់ ការបន្ត ការផ្ទេរ ការផ្អាក ឬបញ្ឈប់គម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍

១២. ពិនិត្យនិងអនុម័តលើថវិកា រួមទាំងថវិកាសម្រាប់ចំណាយជូនរដ្ឋបាលប្រចាំឆ្នាំ និង

១៣. អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់**មូលនិធិ ស.អ.**។

គោលបំណងធំនៃការបង្កើត**មូលនិធិ ស.អ.** ឡើង គឺដើម្បីសហការជាមួយដៃគូនានា ដូចជា ក្រសួងអប់រំ យុវជន និងកីឡា ដែលជាក្រសួងសាមី ក្នុងការស្វែងរកសាលារៀន និងសាកលវិទ្យាល័យនានាដែលត្រូវការជំនួយជាឧបករណ៍បច្ចេកវិទ្យា និងមជ្ឈមណ្ឌលពិសោធបច្ចេកវិទ្យា ព្រមទាំងធ្វើសហការជាមួយប្រតិបត្តិករឯកជននានាដែលជាអ្នកផ្តល់វិភាគទានក្នុងការទ្រទ្រង់មូលនិធិនេះ។

**ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល** info@cbrd.gov.kh